ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ:១៣៣៨ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការបើកបណ្តុះបណ្តាលថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យបាត់ដំបង

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពី លក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពី ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២១ ខែ មីនា ឆ្នាំ២០០៧ ស្តីពី ការបង្កើតសាកលវិទ្យាល័យបាត់ដំបង

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

- បានឃើញអនុក្រឹត្យលេខ ១៥១ អនក្រ. បក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- បានឃើញប្រកាសលេខ ២៩១៤ អយក.ប្រក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ ស្តីពីលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- បានឃើញប្រកាសលេខ ១៤៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពី លក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់បង្កើតគ្រឹះស្ថានឧត្តមសិក្សា
- យោងតាមសំណើរបស់ សាកលវិទ្យាល័យបាត់ដំបង

**សម្រេច**

**ប្រការ១-**

អនុញ្ញាតឱ្យសាកលវិទ្យាល័យបាត់ដំបងបើកបណ្តុះបណ្តាលថ្នាក់បណ្ឌិត ជំនាញ និរន្តរភាព នៃការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី

ត្រូវសិក្សារយៈពេលយ៉ាងតិច ៣(បី)ឆ្នាំ សមមូលនឹង៥៤(ហាសិបបួន)ក្រេឌីតយ៉ាងតិច។

**ប្រការ២-**

សាកលវិទ្យាល័យបាត់ដំបង មានភារកិច្ចៈ

- រៀបចំបទបញ្ញត្តិស្តីពីការគ្រប់គ្រងការសិក្សាសម្រាប់មុខជំនាញខាងលើ
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- អនុវត្តតាមបទដ្ឋានគតិយុត្តិរបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍ស្តីពីការបណ្តុះបណ្តាលមកនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រៀងរាល់ឆមាសឱ្យបានទៀងទាត់។

**ប្រការ៣.**

និស្សិតដែលរៀនចប់កម្មវិធីសិក្សា ហើយបានទទួលជោគជ័យក្នុងការការពារនិក្ខេបបទបញ្ចប់ការសិក្សាត្រូវទទួលសញ្ញាបត្របណ្ឌិតតាមមុខជំនាញដែលបានសិក្សាស្រាវជ្រាវ។ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយសាកលវិទ្យាល័យបាត់ដំបង ផ្អែកតាមបញ្ជីឈ្មោះនិស្សិតបានបញ្ចប់ការសិក្សាជាប់ជាស្ថាពរដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤.**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នាយកដ្ឋានឧត្តមសិក្សា សាកលវិទ្យាល័យបាត់ដំបង និងគ្រប់អង្គភាព ដែលពាក់ព័ន្ធត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៧ ១០ ខែ ឆ្នាំ ច សំរិទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៨

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា

"ដើម្បីជូនជ្រាប"

- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ ន.សវ

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន